ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

**មាត្រា២ .-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ មានតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទនិងមានភារកិច្ចដូចតទៅ៖

- ទទួលបន្ទុកចាត់ការទូទៅ គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពនិងការងារប្រចាំថ្ងៃរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ដឹកនាំសម្របសម្រួលការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រ ក្នុងការលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការគាំពារសង្គម និងកម្មវិធីផ្សេងៗទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ចក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ដឹកនាំសម្របសម្រួល ក្នុងការចូលរួមផ្តល់យោបល់ ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោល-នយោបាយនិងយុទ្ធសាស្ត្រនៃការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការគាំពារសង្គម និងកម្មវិធីផ្សេងៗទៀតដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ដឹកនាំសម្របសម្រួល ប្រមូល វិភាគទិន្នន័យ ធ្វើបច្ចុប្បន្នកម្ម និងផ្សព្វផ្សាយព័ត៌មាននានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងគាំពារសង្គម
- បណ្តុះបណ្តាលជំនាញដើម្បីលើកកម្ពស់សមត្ថភាពនិងការយល់ដឹងដល់បុគ្គលិក មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- សម្របសម្រួលនិងរៀបចំគម្រោងថវិកាសម្រាប់ដំណើរការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

- ប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានរៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទប្រគល់ជូន។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរង ចំនួនច្រើនបំផុត៥(ប្រាំ)រូប ដើម្បីជួយបំពេញការងារ។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមការកំណត់របស់អគ្គលេខាធិការ។

ភារកិច្ចរបស់អគ្គលេខាធិការនិងអគ្គលេខាធិការរង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

**មាត្រា៤ .-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវរៀបចំការប្រជុំយ៉ាងតិច៣(បី)ខែម្តង ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការការងារឱ្យមានភាពរលូន។

**មាត្រា៥ .-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ អាចស្នើសុំទៅប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីជ្រើសរើសទីប្រឹក្សា ជំនួយការ ឬបុគ្គលិកជាប់កិច្ចសន្យាឱ្យមកបំពេញការងារបាន។

**មាត្រា៦ .-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ មានរចនាសម្ព័ន្ធដូចតទៅៈ

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានផែនការនិងសហប្រតិបត្តិការ
- នាយកដ្ឋានសន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខាភិបាល
- នាយកដ្ឋានអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

- នាយកដ្ឋានគ្រប់គ្រងព័ត៌មាន ចំណេះដឹង និងផ្សព្វផ្សាយ
- នាយកដ្ឋានគាំទ្រគោលនយោបាយ
- នាយកដ្ឋានគាំពារសង្គម។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៧ .—**

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធាន១(មួយ)រូបនិងមានអនុប្រធានច្រើនបំផុតពី៣(បី)រូបទៅ ៥(ប្រាំ)រូប។

នាយកដ្ឋាននីមួយៗមានការិយាល័យមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

## ជំពូកទី៤

## តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**មាត្រា៨ .—**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ទទួលខុសត្រូវលើការងាររដ្ឋបាលទូទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ រួមមានសំណុំលិខិតបទដ្ឋានគតិយុត្តនានា ពិធីការ សណ្តាប់ធ្នាប់ អនាម័យជាដើម
- គ្រប់គ្រងឯកសារក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិក និងសម្របសម្រួលលើកិច្ចការពាក់ព័ន្ធផ្នែករដ្ឋបាលសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅគ្រប់អង្គភាពនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ទទួលបន្ទុកចាត់ចែង រៀបចំការងាររដ្ឋបាលពាក់ព័ន្ធនឹងកិច្ចប្រជុំ សិក្ខាសាលា និងទស្សនកិច្ចផ្សេងៗ
- រៀបចំគម្រោងថវិកា សម្ភារៈ និងមធ្យោបាយនានាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គ្រប់គ្រងនិងបែងចែកសម្ភារៈបរិក្ខារជូនគ្រប់អង្គភាពក្រោមឱវាទក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គ្រប់គ្រង ថែទាំ ផ្គត់ផ្គង់ និងធ្វើបញ្ជីសារពើភណ្ឌនៃចលនទ្រព្យនិងអចលនទ្រព្យរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

- គ្រប់គ្រងនិងប្រតិបត្តិថវិកាឱ្យបានត្រឹមត្រូវទៅតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ធ្វើកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពនិងលទ្ធផល ការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា៩ .-**

នាយកដ្ឋានផែនការនិងសហប្រតិបត្តិការ មានតួនាទីនិងភារកិច្ចដូចតទៅៈ

- សម្របសម្រួលនិងសហការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាព របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងរៀបចំដាក់បញ្ចូលឯកសារទាំងអស់ នោះទៅក្នុងឯកសារក្របខ័ណ្ឌគតិយុត្តនានារបស់រាជរដ្ឋាភិបាល
- ចូលរួមសហការផ្តល់យោបល់ ពិនិត្យតាមដាន និងវាយតម្លៃក្នុងការអនុវត្តផែនការនិងលទ្ធផល សម្រេចបានពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ
- ប្រមូលចងក្រងរបាយការណ៍វឌ្ឍនភាពការងារនិងលទ្ធផលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ របស់នាយកដ្ឋានជំនាញនីមួយៗនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- សម្របសម្រួល សហការ និងរៀបចំលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិ ការរវាងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទជាមួយភាគីពាក់ព័ន្ធ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា១០ .-**

នាយកដ្ឋានសន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខាភិបាល មានតួនាទីនិងភារកិច្ចដូចតទៅៈ

- សម្របសម្រួល ចូលរួម និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីលើកកម្ពស់វិស័យសន្តិសុខស្បៀង អាហា-រូបត្ថម្ភ និងសុខាភិបាល/.

- ចូលរួមនិងសម្របសម្រួលរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី គម្រោងផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខាភិបាល
- ចូលរួមសិក្សាស្រាវជ្រាវ ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខាភិបាល
- បណ្តុះបណ្តាលចំណេះដឹងលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន
- សម្របសម្រួល សហការ និងផ្តល់យោបល់លើការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធលើវិស័យសន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខាភិបាល
- បញ្ចូលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានា ជាពិសេសទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ
- គ្រប់គ្រង អភិវឌ្ឍ និងធ្វើបច្ចុប្បន្នកម្មគេហទំព័រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា១១ .-**

នាយកដ្ឋានអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទមានតួនាទីនិងភារកិច្ចដូចតទៅ៖

- សម្របសម្រួល ចូលរួម និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ
- ប្រមូលផ្តុំនិងគ្រប់គ្រងទិន្នន័យ ព័ត៌មាន អំពីស្ថានភាពការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ដើម្បីប្រើប្រាស់ក្នុងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន
- សម្របសម្រួល ចូលរួម និងសហការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ
- សម្របសម្រួល ពិនិត្យ តាមដាន និងវាយតម្លៃរាល់ការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ។

- ជំរុញនិងលើកទឹកចិត្តក្នុងការបញ្ជ្រាបគោលនយោបាយយេនឌ័រ ក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា១២ .–**

នាយកដ្ឋានគ្រប់គ្រងព័ត៌មាន ចំណេះដឹង និងផ្សព្វផ្សាយ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ប្រមូលចងក្រង វិភាគ គ្រប់គ្រង និងផ្សព្វផ្សាយប្រព័ន្ធទិន្នន័យស្ថិតិដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ
- ប្រមូល រៀបចំចងក្រង វិភាគ ផ្សព្វផ្សាយ គ្រប់គ្រង និងថែទាំទិន្នន័យព័ត៌មាន ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ
- រៀបចំបោះពុម្ព ផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានស្តីពីសកម្មភាពរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- សហការរៀបចំ ចងក្រង និងផ្សព្វផ្សាយ ទិន្នន័យ ព័ត៌មាន ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា
- តាមដាននិងគ្រប់គ្រងប្រព័ន្ធព័ត៌មាននៃសកម្មភាពការងាររបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្មនិងជនបទ
- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សលើវិស័យបច្ចេកវិទ្យាព័ត៌មានសម្រាប់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ចូលរួមផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្រ្ត និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ
- ធ្វើរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា១៣ .–**

នាយកដ្ឋានគាំទ្រគោលនយោបាយ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ផ្តល់ប្រឹក្សា ពិគ្រោះយោបល់ ពិនិត្យ និងពិភាក្សាគោលនយោបាយជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន
- ចូលរួមកំណត់យុទ្ធសាស្ត្រអាទិភាព និងសូចនាករពីឯកសារគោលនយោបាយនានា ជាអាទិ៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ
- ចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនៅមូលដ្ឋាន
- វិភាគនិងតាមដានការវិវត្តគោលនយោបាយថ្មីៗនៅកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់ និងសកល ដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចសង្គម
- កសាងភាពជាដៃគូនិងបណ្តាញនៃកិច្ចសន្ទនាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជនដែលទាក់ទងនឹងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ជំរុញនិងលើកទឹកចិត្តក្នុងការបញ្ជ្រាបគោលនយោបាយយេនឌ័រ ក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា១៤ .-**

នាយកដ្ឋានគាំពារសង្គម មានតួនាទីនិងភារកិច្ចដូចតទៅៈ

- លើកកម្ពស់ការយល់ដឹង ផ្សព្វផ្សាយទស្សនាទាន និងខ្លឹមសារនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍ ដោយជំរុញឱ្យមានការផ្តល់សេវាគាំពារសង្គមក្នុងកម្រិតអប្បបរមាសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះ និងការពង្រីកវិសាលភាពនៃរបបសន្តិសុខសង្គមជាលក្ខណៈសកល
- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីកិច្ចគាំពារសង្គមដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជាមូលដ្ឋានក្នុងការបញ្ជ្រាបកម្មវិធីគាំពារសង្គមទៅក្នុងផែនការអភិវឌ្ឍន៍របស់ខ្លួន
- បង្កើនប្រសិទ្ធភាពនៃការប្រមូល ការចងក្រង ការវិភាគ និងការចែករំលែកព័ត៌មាន ទិន្នន័យ គោលនយោបាយ បទពិសោធ និងគំនិតផ្តួចផ្តើមនានា ដែលពាក់ព័ន្ធនឹងវិស័យគាំពារសង្គមទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន

- ធ្វើបច្ចុប្បន្នកម្មលើការពិនិត្យតាមដានលើលទ្ធផលនៃការគាំពារសង្គម ដោយអនុលោមទៅតាមសូចនាករពិនិត្យតាមដានការគាំពារសង្គម និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- រៀបចំបង្កើត អនុវត្ត និងផ្សព្វផ្សាយយន្តការនៃការផ្តល់សេវាសង្គម នៅថ្នាក់ក្រោមជាតិឱ្យស្របទៅតាមអភិបាលកិច្ចល្អ
- សម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍ ក្នុងការអនុវត្តកម្មវិធីឬអន្តរាគមន៍សេវាគាំពារសង្គមក្នុងកម្រិតសាកល្បង និងការពង្រីកវិសាលភាពដើម្បីចងក្រងបទពិសោធ ការវាយតម្លៃផលប៉ះពាល់ និងដាក់ចេញជាអនុសាសន៍ផ្នែកគោលនយោបាយ
- ជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងការអនុវត្តកម្មវិធីគាំពារសង្គមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា១៥ .-**

មន្ត្រីរាជការដែលបានទទួលការតែងតាំងមុនអនុក្រឹត្យនេះចូលជាធរមាន នៅរក្សាមុខតំណែងនិងបុព្វសិទ្ធិដដែល រហូតដល់មានការតែងតាំងសាជាថ្មីស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

អនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការរៀបចំសមាសភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ៣ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៨២អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៥

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

**អគ្គលេខាធិការដ្ឋាន**

- *នាយកដ្ឋាន* រដ្ឋបាល និងហិរញ្ញវត្ថុ
- *នាយកដ្ឋាន* ផែនការ និង សហប្រតិបត្តិការ
- *នាយកដ្ឋាន* សន្តិសុខស្បៀង អាហារូបត្ថម្ភ និងសុខាភិបាល
- *នាយកដ្ឋាន* អភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ
- *នាយកដ្ឋាន* គ្រប់គ្រងព័ត៌មាន ចំណេះដឹង និង ផ្សព្វផ្សាយ
- *នាយកដ្ឋាន* គាំទ្រ គោលនយោបាយ
- *នាយកដ្ឋាន* គាំពារសង្គម